ASRIC
Applied Social Research Institute of Cambodia

THE CENTER FOR JUSTICE & ACCOUNTABILITY
Bringing Human Rights Abusers To Justice.

ថ្ងៃទី១៣ខែសីហាឆ្នាំ២០១១

មកដល់ដើមបណ្តឹងរដ្ឋប្បវេណីជាទីគោរព:

នេះជាសេចក្តីបន្ថែមថ្មីមួយទៅលើការវិវឌ្ឍន៍នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ទាំងវិទ្យាស្ថានស្រាវជ្រាវអនុវត្តន៍សង្គមកម្ពុជា(ASRIC) និងមជ្ឈមណ្ឌលយុត្តិធម៌ និងគណនីភាព (CJA) បានចូលរួមសវនការដំបូងដែលប្រព្រឹត្តចាប់ពីថ្ងៃទី២៧ ខែមិថុនា ដល់ថ្ងៃទី៣០ ខែមិថុនា។ ក្នុងចំណោមអ្នកទាំងអស់គ្នាមានអ្នកមួយចំនួនត្រូវបានទាក់ទងជាបុគ្គលតាមរយៈដៃគូផ្នែកច្បាប់របស់វិទ្យាស្ថានស្រាវជ្រាវអនុវត្តន៍សង្គមកម្ពុជាដែលជាមជ្ឈមណ្ឌលយុត្តិធម៌ និងគណនីភាព។ វិទ្យាស្ថានស្រាវជ្រាវអនុវត្តន៍សង្គមកម្ពុជាបានជ្រើសរើសយកមជ្ឈមណ្ឌលយុត្តិធម៌ និងគណនីភាព ដើម្បីតំណាងអោយអ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យរបស់វិទ្យាស្ថានស្រាវជ្រាវអនុវត្តន៍សង្គមកម្ពុជានៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាហើយយើងនឹងធ្វើការរួមគ្នាដើម្បី ផ្តល់នូវពត៌មានថ្មីៗដល់អ្នកទាំងអស់គ្នាចំពោះការវិវត្តន៍នៃបណ្តឹង។ដោយសារតែអ្នកទាំងអស់គ្នា គឺជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ មជ្ឈមណ្ឌលយុត្តិធម៌និងគណនីភាពនឹងតំណាងផលប្រយោជន៍អោយអ្នកទាំងអស់គ្នាមុននឹងចូលរួមក្នុងតុលាការ ក៏ដូចជាស្វែងរកនូវការទទួលស្គាល់ និងយុត្តិធម៌ក្នុងនាមជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងរស់នៅសហរដ្ឋអាមេរិក។ វិទ្យាស្ថានស្រាវជ្រាវអនុវត្តន៍សង្គមកម្ពុជា និងមជ្ឈមណ្ឌលយុត្តិធម៌ និងគណនីភាព នឹងធ្វើការដើម្បីរក្សាទុកសំណងដែលបានមកពីតុលាការដែលដោះស្រាយនូវការរងទុក្ខទោស និងការឈឺចាប់ដែលអ្នកទាំងអស់គ្នាបានឆ្លងកាត់ក្នុងរបបខ្មែរក្រហម។

ដូចដែលអ្នកធ្លាប់បានដឹងហើយថា សវនការដំបូងដែលពាក់ព័ន្ធជាមួយចុងចោទទាំងបួននាក់ក្នុងសំណុំរឿង០០២ ដែលរួមមាន នួន ជា អៀង សារី អៀង ធីរិទ្ធ ខៀវ សំផន ត្រូវបានប្រព្រឹត្តនៅក្នុងខែមិថុនា។ សវនការទាំងនេះផ្តល់ឱកាសអោយចៅក្រមក្នុងការពិចារណាទៅលើឧបសគ្គនានាដែលអាចកើតមានចំពោះនិតិវិធីតុលាការ ឬនិតិវិធីមុននឹងអង្គហេតុ និងអង្គច្បាប់ត្រូវបង្ហាញក្នុងសំណុំរឿង០០២។ បន្ថែមពីនេះទៅទៀត តុលាការប្រើប្រាស់សវនការដំបូងទាំងនេះដើម្បីធ្វើការពិភាក្សាវែកញែកបញ្ហានៃការរៀបចំការកាត់ក្តី ដូចជាសំណងសំរាប់ដើមបណ្តឹងរដ្ឋប្បវេណី ប្រភេទនៃអង្គច្បាប់ដែលនឹងអនុញ្ញាតអោយមាននៅពេលកាត់ក្តី សាក្សី និងអ្នកជំនាញដែលនឹងត្រូវហៅមកធ្វើជាកសិណសាក្សីមុនតុលាការចាប់ផ្តើម។ ជាមួយនឹងចំនួនអង្គហេតុ និងអង្គច្បាប់ក្នុងសំណុំរឿង០០២ ការកាត់ក្តីទំនងជាចាប់ផ្តើមក្នុងខែកញ្ញា ឬដើមខែតុលា។ ជាមួយគ្នានេះដែរ ក៏មានសវនការជាច្រើនទៀតមុននឹងការកាត់ក្តីនេះ ហើយវិទ្យាស្ថានស្រាវជ្រាវអនុវត្តន៍សង្គមកម្ពុជា និងមជ្ឈមណ្ឌលយុត្តិធម៌និងគណនីភាពនឹងជូនដំណឹងដល់លោកអ្នក នៅពេលដែលការកាត់ក្តីជាផ្លូវការត្រូវបានកំណត់ថា ចាប់ផ្តើមនៅពេលណា។

ASRIC,c/o A/P/A Institute NYU, 41-51 E. 11th Street, New York, NY 10003, tel (212) 300-5775www.apa.nyu.edu/ASRIC;
CJA, 870 Market Street, Suite 680 San Francisco, CA 94102, tel (415) 544 0444, fax (415) 544 0456 www.cja.org

ក្នុងកំឡុងពេលសវនការយើងបានសង្កេតឃើញមាននូវការជជែកវែកញែករកហេតុផលជាច្រើនដែលលើកឡើងដោយចុងចោទក្នុងករណីនេះ។ កថាខណ្ឌខាងក្រោម គឺជាសេចក្តីសង្ខេបនៃការការជជែកវែកញែករកហេតុផលដែលលើកឡើងដោយមេធាវីចុងចោទ និងការឆ្លើយតបរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ អ្នកទាំងអស់គ្នាអាចស្វែងយល់នូវនិយមន័យនៃពាក្យគតិយុត្តិ ដោយមានសញ្ញា [*] ជាសំគាល់នូវទំព័រចុងក្រោយនៃសេចក្តីបន្ថែមថ្មីនេះ។

ជាបឋមនេះ មេធាវីរបស់ អៀង សារី បានលើកឡើងថា កូនក្តីរបស់ខ្លួនត្រូវបានកាត់ទោសរួចទៅហើយមុននឹងសាលាក្តីបដិវត្តប្រជាជនកម្ពុជាក្នុងឆ្នាំ១៩៧៩ ដូចនេះហើយពុំអាចទទួលការកាត់ក្តីម្តងទៀតដោយអង្គជំនុំជម្រះតុលាការវិសាមញ្ញក្នុងតុលាការកម្ពុជាបានទេ។ ជាធម្មតា បុគ្គលត្រូវបានការពារមិនអោយទទួលការកាត់ក្តីពីរដងចំពោះបទឧក្រិដ្ឋដដែលទេ។ ការការពារនេះត្រូវបានគេហៅថា ជា"គោលការណ៍កាត់ទោសមួយដងក្នុងអង្គហេតុតែមួយ"*។ មេធាវីដើមចោទ* និងមេធាវីសំរាប់ដើមបណ្តឹងរដ្ឋប្បវេណី*បានឆ្លើយតបដោយនិយាយថា ការកាត់ក្តីក្នុងឆ្នាំ១៩៧៩មិនមានជាលក្ខណៈស្តង់ដាសំរាប់ការកាត់ក្តីដោយយុត្តិធម៌នោះទេដូចនេះការកាត់ក្តីនាពេលនេះ មិនគួរត្រូវបានបញ្ឈប់ឡើយ។

ទីពីរ មេធាវីការពារ អៀង សារី បាននិយាយថា កូនក្តីពួកគេត្រូវបានលើកលែងទោសចំពោះបទឧក្រិដ្ឋរបស់ខ្លួនដោយ ព្រះមហាក្សត្រសីហនុ និងព្រឹទ្ធសភាជាតិ ក្នុងឆ្នាំ១៩៩៦។ ការកាពារមិនអោយមានការកាត់ក្តីប្រភេទនេះត្រូវបានគេហៅថា "ការលើកលែងទោស"*។ មេធាវីដើមចោទ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតបវិញថា ការលើកលែងទោសរបស់ព្រះមហាក្សត្រ មិនត្រូវបានអនុវត្តចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ និងការធ្វើទារុណកម្មដែលកំពុងតែត្រូវបានធ្វើសវនការដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះទេ។ លើសពីនេះទៅទៀតពួកគេបាននិយាយទៀតថា នៅក្រោមច្បាប់អន្តរជាតិ បទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរបែបនេះមិនអាចធ្វើការលើកលែងទោសបានទេ ហើយអ្នកដែលបានប្រព្រឹត្តនូវបទឧក្រិដ្ឋបែបនេះត្រូវតែប្រឈមមុខនឹងការកាត់ទោសជាដាច់ខាត។

ការប្រឆាំងតវ៉ាទីបីដែលលើកឡើងដោយចុងចោទ* (អ្នកដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង០០២) ព្រួយបារម្មណ៍ថា តើរយៈពេលដែលអនុញ្ញាតអោយមានការនាំសំណុំរឿងបែបនេះមកកាត់ក្តីបានផុតកំណត់ហើយរឺនៅ។ ក្រោមនិតិកម្ពុជា បុគ្គលម្នាក់មិនអាចនាំទៅកាត់ក្តីបានទេ ចំពោះបទឧក្រិដ្ឋដែលបានកើតឡើងអស់រយៈពេលជាង ១០ឆ្នាំទៅហើយ។ វិធាននេះហៅថា "លក្ខន្តិកៈនៃរយៈពេលអាជ្ញាយុកាល"*។ ទោះជាយ៉ាងណាក៏ដោយ មេធាវីដើមចោទ និងមេធាវីដើមបណ្តឹង រដ្ឋប្បវេណីបានប្រកែកវិញថាវិធាននេះគឺអនុវត្តតែចំពោះករណីក្នុងតុលាការកម្ពុជាតែប៉ុណ្ណោះ។ ដោយសារតែអង្គជំនុំជំរះតុលាការវិសមញ្ញកម្ពុជា គឺជាតុលាការពិសេសមួយ ដែលធ្វើសវនាការលើករណីនៃច្បាប់អន្តរជាតិ ដូចនេះវិធាននេះមិនគួរអនុវត្តទេ។

ទីបួន នៅថ្ងៃចុងក្រោយនៃសវនាការ ចៅក្រមបានពិភាក្សាអំពីសាក្សី និងអ្នកជំនាញដែលនឹងប្រហែលជាត្រូវឆ្លើយក្នុងដំណាក់កាលដំបូងនៃការកាត់ក្តី។ សាក្សី និងអ្នកជំនាញទាំងនេះនឹងនិយាយអំពីរចនាសម្ព័ន្ធ និងគោលនយោបាយនៃគណបក្សកុំម្មុយនីស និងកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជា

តួនាទី និងទំនួលខុសត្រូវនៃចុងចោទនីមួយៗ ចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩។ នៅត្រង់ចំណុចនេះ ចុងចោទ ខៀវ សំផន (អតីតប្រមុខដឹកនាំរដ្ឋកម្ពុជាប្រជាធិបតេយ្យ) បានមកស្វាគមន៍អ្នកចូលរួមក្នុងតុលាការហើយបាននិយាយថា គាត់បានរង់ចាំការកាត់ក្តីនេះជាយូរណាស់មកហើយ ព្រមទាំងបានសន្យាថានឹងជួយសំរួលការងារតុលាការដើម្បីស្វែងរកការពិត។ ចុងចោទនីមួយៗបានសំណូមពរដល់ចៅក្រមអោយអនុញ្ញាតសាក្សីពួកគេធ្វើជាកសិណសាក្សីអោយពួកគេក្នុងកំឡុងពេលនៃការកាត់ក្តី។ ចៅក្រមនឹងធ្វើការសំរេចចិត្តលើបញ្ហានេះក្នុងរយៈពេលមួយ ឬពីរខែទៀត។ វិទ្យាស្ថានស្រាវជ្រាវអនុវត្តន៍សង្គមកម្ពុជា និងមជ្ឈមណ្ឌលយុត្តិធម៌ និងគណនីភាព នឹងជូនជាដំណឹងដល់អ្នកទាំងអស់គ្នាករណីដែលមានការផ្លាស់ប្តូរសំខាន់ៗដែលកើតឡើងដោយសារលទ្ធផលនៃការសំរេចចិត្តនេះ។

ចុងក្រោយ ចៅក្រមបានស្តាប់សេចក្តីថ្លែងការមួយដែលធ្វើឡើងដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអំពីសំណង*។ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងនេះ អ្នកទាំងអស់គ្នាមានសិទ្ធិក្នុងការទទួលបាននូវសំណងមិនមែនជាប្រាក់កាសពីតុលាការ ប្រសិនបើចុងចោទត្រូវបានរកឃើញថាមានកំហុស។ សំណងនេះមានលក្ខណៈជាសមូហភាព និងជានិមិត្តរូបតំណាងមានន័យថាសំណងនេះត្រូវបានបង្កើតឡើងដើម្បីជាប្រយោជន៍ដល់អ្នករស់រានមានជីវិតភាគច្រើន និងមានគោលបំណងជារូបតំណាងមួយ ដែលបង្ហាញអំពីការស្វែងរកដំណោះស្រាយចំពោះការធ្វើ ទុក្ខទោសទៅដល់ជនរងគ្រោះក្នុងសម័យខ្មែរក្រហម។

វិទ្យាស្ថានស្រាវជ្រាវអនុវត្តន៍សង្គមកម្ពុជា និងមជ្ឈមណ្ឌលយុត្តិធម៌ និងគណនីភាពបានធ្វើជូនអោយអ្នកទាំងអស់គ្នានូវការស្ទង់មតិអំពីសំណង ក្នុងខែមីនា ឆ្នាំ២០១១។ បន្ទាប់ពីបានរៀបចំជាតារាងលទ្ធផលនៃការស្ទង់មតិ យើងបានរកឃើញថា ភាគច្រើនដើមបណ្តឹងរដ្ឋប្បវេណីត្រូវការសំណង ១- ដែលអាចរក្សារទុកនូវភស្តុតាងនៃបទឧក្រិដ្ឋដែលប្រព្រឹត្តដោយខ្មែរក្រហម ២- ដែលធានាថាសាធារណជនទូទៅមានការយល់ដឹងអំពីលក្ខណៈ និងវិសាលភាពនៃបទឧក្រិដ្ឋនេះ។ ជាពិសេសជាងនេះទៅទៀត មានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការបង្កើតជាសារមន្ទីរដើម្បីអប់រំដល់សាធារណជនទូទៅអំពីរបប ប៉ុលពត ព្រមទាំងជនរងគ្រោះ ក៏ដូចជាការបង្កើតនូវរូបសំណាកគោរពទៅដល់ជនរងគ្រោះនៃរបបខ្មែរក្រហម។

ក្នុងកំឡុងពេលសវនការដំបូងនេះមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ទៅកាន់តុលាការថា សំណងគឺជាសិទ្ធិរបស់ជនរងគ្រោះ ហើយក៏បានពិពណ៌នាអំពីសំណងទាំងបួនប្រភេទដែលដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំ ១- ការសាងសង់សំណាកសំរាប់រំលឹក និងវត្ថុសំរាប់ការចងចាំជាអនុស្សាវរីយ៍ ២-ការធ្វើអោយមានភាពល្អប្រសើរឡើងវិញ ៣- ការចងក្រងនូវឯកសារនិងការអប់រំ ៤- និងសំណងផ្សេងៗទៀត។ គំរោងនៃសំណងមួយចំនួនដែលជាឧទាហរណ៍ចំពោះប្រភេទនៃសំណងទាំងនេះរួមមាន ទីកន្លែងសំរាប់ការរំលឹក ការអភិរក្សវាលពិឃាត សេវាព្យាបាលផ្លូវចិត្តសំរាប់ជនរងគ្រោះ កម្មវិធីសិក្សាស្តីអំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ ការបង្កើតនូវបណ្ណសារសំរាប់ជាភស្តុតាង និងជាសក្ខីភាពនៃជនរងគ្រោះ បញ្ជីឈ្មោះជនរងគ្រោះ និងសារមន្ទីរសំរាប់អប់រំសាធារណជនអំពីខ្មែរក្រហម។ មេធាវីសំរាប់ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់បន្ថែមទៀតថា

នេះមិនមែនជាការស្នើរសុំសំណាងចុងក្រោយទេ ហើយការស្នើរសុំអាចមានការផ្លាស់ប្តូរបន្ទាប់ពីមានការប្រឹក្សារជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីមុននឹងមានការកាត់ក្តីជាចុងក្រោយ។

ប្រសិនបើអ្នកទាំងអស់គ្នាមានសំណួរ ឬចំងល់អ្វីពាក់ព័ន្ធនឹងសំណើរនៃសំណាង សូមទាក់ទងមកកាន់ លោកស្រីបណ្ឌិត **លក្ខិណា នូ** នៃវិទ្យាស្ថានស្រាវជ្រាវអនុវត្តន៍សង្គមកម្ពុជា។ យើងសូមស្វាគមន៍រាល់គំនិតរបស់អ្នកទាំងអស់គ្នា ហើយធានាថា វិទ្យាស្ថានស្រាវជ្រាវអនុវត្តន៍សង្គមកម្ពុជានឹងប្រគល់នូវពត៌មានដែលអ្នកទាំងអស់គ្នាបានផ្តល់ទៅកាន់មេធាវីរបស់អ្នកទាំងអស់គ្នាដែលមានឈ្មោះថា សាការ៉ាទី នូស៊ីន (SARKARATI Nushin) ដែលជាមេធាវីប្រចាំនៅមជ្ឈមណ្ឌលយុត្តិធម៌និងគណនីកិច្ចហើយគាត់នឹងបញ្ចូលរាល់គំនិតទាំងនេះ ក្នុងការពិភាក្សារលើសំណាងមុននឹងមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ដូចជាអ្វីដែលយើងបានពន្យល់ពីមុនមក មជ្ឈមណ្ឌលយុត្តិធម៌ និងគណនីកិច្ចនឹងផ្តល់អោយអ្នកទាំងអស់គ្នានូវអ្នកតំណាងផ្នែកច្បាប់នៅក្នុងពាក្យបណ្តឹងទាំងនេះ ដោយមិនយកប្រាក់អ្វីឡើយ។ សូមទំនាក់ទំនងមកកាន់ **សាកាវ៉ាទី នូស៊ីន** (SARKARATI Nushin) ប្រសិនបើអ្នកមានសំណួរ ឬចំងល់អ្វីមួយទាក់ទងនឹងបណ្តឹងផ្នែកច្បាប់ ឬក៏ទាក់ទងនឹងតួនាទីរបស់អ្នកទាំងអស់គ្នាក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីតាមរយៈលេខទូរស័ **(415) 544-0444** បន្តទៅកាន់ **318** ឬតាមរយៈ e-mail **៖** **nsarkarati@cja.org**។ មជ្ឈមណ្ឌលយុត្តិធម៌ និងគណនីកិច្ចរង់ចាំដោយក្តីរីករាយក្នុងការធ្វើជាអ្នកតំណាងផលប្រយោជន៍អោយអ្នកទាំងអស់គ្នាក្នុងសវនការកាត់ក្តីខាងមុខនេះ។

ប្រសិនបើអ្នកមានបំណងចង់ពិភាក្សាអំពីបញ្ហាផ្ទាល់ខ្លួន និង/ឬដំណើរការនៃការត្រលប់មកសភាពល្អប្រសើរដូចដើមវិញ បញ្ហាសមាគមន៍នានាដែលទាក់ទងទៅនឹងសាលាក្តី សូមទាក់ទងមកកាន់លោកស្រីបណ្ឌិត **នូ លក្ខិណា** ដែលជានាយកប្រតិបត្តិនៃវិទ្យាស្ថានស្រាវជ្រាវអនុវត្តន៍សង្គមកម្ពុជាតាមរយៈលេខ (**212) 300-5775** ឬតាមរយៈ e-mail**៖** **apa.asric-khmer.justice@nyu.edu**។

ដោយសេចក្តីគោរពយ៉ាងស្មោះត្រង់ពីយើងខ្ញុំ

| | |
|---|---|
| **Ms. Nushin SARKARATI** | **បណ្ឌិតលក្ខិណា នូ** |
| មេធាវីអន្តរជាតិសំរាប់ដើមបណ្តឹងរដ្ឋប្បវេណីនៃ | នាយកប្រតិបត្តិ |
| អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា | វិទ្យាស្ថានស្រាវជ្រាវអនុវត្តន៍សង្គមកម្ពុជា |
| មេធាវីប្រចាំនៅមជ្ឈមណ្ឌលយុត្តិធម៌និងគណនីកិច្ច | |

# សទ្ទានុក្រមនៃពាក្យ

**ដើមបណ្តឹងរដ្ឋប្បវេណី** - (civil party) ៖
គឺជាអ្នកចូលរួមផ្លូវការម្នាក់ក្នុងពាក្យបណ្តឹងដែលប្រឆាំងទៅនឹងជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់នូវបទឧក្រិដ្ឋក្រោមការសើបអង្កេតដោយ អ.វ.ត.ក. (ECCC) និងពួកគេមានសិទ្ធិស្រដៀងទៅនឹងសិទ្ធិរបស់មេធាវីដើមចោទហើយនិងមេធាវីចុងចោទ។ ការក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីមិនត្រឹមតែអាចផ្តល់សិទ្ធិដល់ជនរងគ្រោះចូលរួមក្នុងការដាក់ពាក្យបណ្តឹងតែប៉ុន្មោះទេ ហើយថែមទាំងអាចអនុញ្ញាតអោយពួកគេអាចស្នើរសុំតុលាការនូវសំណងពី ទណ្ឌិតទៀតផង។

**អ្នកដាក់ពាក្យបណ្តឹងធម្មតា** - (complainant) ៖
នៅក្នុងនីតិវិធីរបស់ អ.វ.ត.ក គាត់ជារូបវន្តបុគ្គលដែលបានដាក់ពាក្យបណ្តឹង ហើយដែលពាក្យបណ្តឹងនេះអាចត្រូវបានប្រើប្រាស់ក្នុងការស៊ើបអង្កេតទៅលើឧក្រិដ្ឋកម្ម ដែលត្រូវ បានចោទប្រកាន់ប្រឆាំងទៅនឹងជនជាប់ចោទ។ អ្នកដាក់ពាក្យបណ្តឹងធម្មតាមិនចូលរួមក្នុងនីតិវិធីសវនាការក្នុង ឋានៈជាភាគីនោះទេ ហើយគាត់ក៏មិនមានសិទ្ធិក្នុងការស្នើសុំសំណងដែល ត្រូវសម្រេចដោយតុលាការដែរ។ ទោះបីយ៉ាងណាក្តី គាត់អាចត្រូវបានស្នើសុំឲ្យផ្តល់ភស្តុតាង ឬធ្វើសក្ខីកម្មក្នុងឋានៈជាសាក្សីបាន។

**អាជ្ញាយុកាល** - (statute of limitations) ៖
ជាច្បាប់ដែលធ្វើការរឹតបណ្តឹងទៅលើរយៈពេលដែលពាក្យបណ្តឹងអាចត្រូវបានដាក់ចូលក្នុងសំណុំរឿងមួយ។

**គោលការណ៍កាត់ទោសមួយដងក្នុងអង្គហេតុតែមួយ** - (double jeopardy) ៖
ជាគោលការណ៍មួយដែលអនុញ្ញាតអោយបុគ្គលម្នាក់មិនត្រូវបានកាត់ទោសចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្ត ដោយសារតែបុគ្គលម្នាក់នោះត្រូវបានកាត់ទោសអោយជាប់ទោស
រឺត្រូវបានរួចខ្លួនពីការចោទប្រកាន់រួចហើយ។

**មេធាវីដើមចោទ** - (prosecutor) ៖
គឺជាភាគីស្របច្បាប់មួយរូបដែលទទួលខុសត្រូវលើការបង្ហាញសំណុំរឿងក្នុងការកាត់ក្តីបទឧក្រិដ្ឋមួយដែលប្រឆាំងទៅនឹងបុគ្គលដែលត្រូវបានចោទប្រកាន់លើការរំលោភច្បាប់អ្វីមួយ។

**មេធាវីសំរាប់ដើមបណ្តឹងរដ្ឋប្បវេណី** - (lawyer for civil parties) ៖
នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមេធាវីសំរាប់ដើមបណ្តឹងរដ្ឋប្បវេណីគឺជាអ្នកទទួលខុសត្រូវតំណាងអោយដើមបណ្តឹងរដ្ឋប្បវេណី និងធ្វើការគាំទ្រសំណុំរឿងរបស់មេធាវីដើមចោទដើម្បីប្រឆាំងទៅនឹងចុងចោទ។

**ការលើកលែងទោស - (amnesty) ៖**
ជាសេចក្តីសម្រេចផ្លូវការមួយធ្វើឡើងដោយរាជរដ្ឋាភិបាលដែលលើកលែងដល់បុគ្គលមួយ រឺច្រើនរូបដែលត្រូវបានចោទប្រកាន់ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋកម្មមិនអោយមានការកាត់ទោសចំពោះការប្រព្រឹត្តបទឧក្រិដ្ឋកម្មមួយនោះ។

**ចុងចោទ - (defendant) ៖**
ក្នុងសំណុំរឿងបទឧក្រិដ្ឋដូចជាសំណុំរឿងផ្សេងៗទៀតមុនអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា ចុងចោទជាបុគ្គលមួយ រឺច្រើនរូបដែលត្រូវបានចោទប្រកាន់ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋអ្វីមួយ។

**សំណង - (reparations):**
ក្នុងច្បាប់សំណងគឺជាខ្នាតរង្វាស់ដែលបង្គាប់ដោយតុលាការដើម្បីធ្វើការសងចំពោះការបង្ករអោយមានជាការគ្រោះថ្នាក់ រឺរបួសស្នាមទៅដល់ជនរងគ្រោះនៃបទឧក្រិដ្ឋមួយដែលបង្ករជនឧក្រិដ្ឋនោះ។